# កិច្ចវត្តព្រះសង្ឃគង់ចាំព្រះវស្សា

តាមទំនៀមជាប្រពៃណីនៃពុទ្ធសាសនិកក្នុងសង្គមខ្មែរ ទាំងរាស្ត្រសាមញ្ញ និងព្រះមហាក្សត្រ តែងរៀបចំប្រគេនទៀនព្រះវស្សា និងអារាធនាព្រះសង្ឃ "ចូលព្រះវស្សា" និង "គង់ចាំព្រះវស្សា" ដែលកំណត់ពីថ្ងៃ ១រោច ខែអាសាឍ[1] (រវាងខែកក្កដា) ដល់ថ្ងៃ ១៥កើត ខែអស្សុជ (រវាងខែកញ្ញា)។ ក្នុងរយៈពេលបីខែនេះ ព្រះសង្ឃដែលគង់ចាំព្រះវស្សាក្នុងវត្តនីមួយៗ តែងគោរពប្រតិបត្តិកិច្ចវត្តតាមក្រឹត្យវិន័យយ៉ាងខ្ជាប់ខ្ជួន ទៅតាមពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាត បើពុំនោះសោតទេ សមណសង្ឃទាំងឡាយនឹងត្រូវអាបត្តិ។[2] មិនតែប៉ុណ្ណោះ ក្នុងវេលាគង់ចាំព្រះវស្សា ព្រះសង្ឃបានឱកាសសិក្សាប្រតិបត្តិធម៌វិន័យហ្មត់ចត់ ម៉ឺងម៉ាត់ពិសេសផ្នែកគន្ថធុរៈ ពោលគឺការសិក្សាគម្ពីរព្រះត្រៃបិដក និងវិបស្សនាធុរៈ ដែលបានដល់ការធ្វើសមាធិចម្រើនធម៌ដើម្បីឃើញច្បាស់នូវសេចក្តីពិតក្នុងលោក ជម្រះនូវគ្រឿងមន្ទិលសៅហ្មងក្នុងចិត្ត។

ជាការពិតហេតុនៃការប្រារព្ធចូលព្រះវស្សា ឬគង់ចាំព្រះវស្សាក្នុងព្រះពុទ្ធសាសនាមានសេចក្តីលើកឡើងស្រដៀងគ្នាថា ក្នុងដើមសម័យពុទ្ធកាលការគង់ចាំព្រះវស្សារបស់ព្រះសង្ឃពុំទាន់បញ្ញត្តិឡើយ ដោយព្រះសង្ឃអាចនិមន្តទៅកាន់ទីផ្សេងៗបានគ្រប់ពេលវេលា។ ឃើញបែបនេះមនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណៈជាសាក្យបុត្តិយ៍ មិនសមនឹងដើរ (ខុសរដូវកាល) ជាន់ស្មៅស្រស់ ជាន់សត្វល្អិតៗឱ្យវិនាសសោះ។ សូម្បីអ្នកកាន់លទ្ធិដទៃក៏គង់សម្ងំឈប់សម្រាកចាំវស្សា ឬសូម្បីពួកសត្វស្លាបទៀតសោតក៏គង់ធ្វើសំបុកលើចុងឈើ ហើយសម្ងំឈប់សម្រាកក្នុងវស្សាដែរ។ ពេលមនុស្សទាំងឡាយកំពុងលើកទោសបែបនេះ ពួកភិក្ខុទាំងនោះក៏បានឮច្បាស់នឹងត្រចៀកផ្ទាល់ ហើយនាំសេចក្តីទៅទូលព្រះសម្ពុទ្ធ។ ព្រះអង្គទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុចូលវស្សា។[3]

---

[1] តាមចន្ទគតិ ក្នុងឆ្នាំខ្លះមានខែអាសាឍពីរលើក (អធិកមាស) ពោលគឺបឋមាសាឍ និងទុតិយាសាឍ។ ប៉ុន្តែទោះជាបែបនេះ ការកំណត់ចូលព្រះវស្សាក៏យកត្រឹមថ្ងៃ ១រោច ខែទុតិយាសាឍដដែល។

[2] អាបត្តិ គឺជាទោសកើតពីការប្រព្រឹត្តកន្លងរំលងសិក្ខាបទរបស់ព្រះសម្មាសម្ពុទ្ធ។

[3] ចាន់ សុជន ២០១៣: ៤-៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ផ្អែកលើការសិក្សាក្នុងពុទ្ធប្រវត្តិក៏បានឱ្យដឹងដែរថា ក្រោយពីព្រះសម្មាសម្ពុទ្ធទ្រង់បានសម្ដែងនូវព្រះធម្មចក្កប្បវត្តនសូត្រ "ប្រោសបញ្ចវគ្គីយ៍ភិក្ខុ" (រូបលេខ១) នៅថ្ងៃ១៥កើត ខែអាសាឍរួចហើយ ព្រះអង្គបន្តគង់នៅព្រៃឥសិបតនមិគទាយវ័នចំនួន៣ខែ រហូតផុតរដូវវស្សា។ ទំនៀមនេះបានប្រព្រឹត្តទៅជាទម្លាប់របស់ព្រះពុទ្ធអង្គក្នុងការគង់នៅមួយកន្លែងរយៈពេល៣ខែក្នុងរដូវវស្សា រហូតក្រោយមកព្រះសម្មាសម្ពុទ្ធក៏អនុញ្ញាតឱ្យភិក្ខុនិងសាមណេរទាំងឡាយនៅគង់ជាប្រចាំនៅតាមវត្ត ឬកន្លែងណាមួយរយៈពេល៣ខែនារដូវវស្សា ហើយដែលសង្គមខ្មែរហៅថា "ព្រះសង្ឃគង់ចាំព្រះវស្សា"។

តាមទម្លាប់ខ្មែរ នៅក្នុងឱកាសអារាធនាព្រះសង្ឃចូលព្រះវស្សា ពុទ្ធបរិស័ទតែងតែនាំយកនូវទេយ្យទានផ្សេងៗ ប្រគេនព្រះសង្ឃប្រើប្រាស់ក្នុងវេលាគង់ចាំព្រះវស្សាដូចជា ទៀន ធូប ប្រេង ស្បង់ ចីវរ សំពត់សាដក អង្ករ ទឹកត្រី ទឹកស៊ីអ៊ីវ និងគ្រឿងសម្ភារៈដទៃទៀតដែលរាប់ទុកជាបច្ច័យបួន។ ប៉ុន្តែអ្វីដែលគេសម្គាល់ឃើញសំខាន់ជាពិសេសជាងគេ គឺទៀនព្រះវស្សា ដែលគេតែងនិយាយថាជាវត្ថុសំខាន់ ត្រូវមានខ្នាតត្រឹមត្រូវ ហើយប្រើសម្រាប់អុជនៅក្នុងព្រះវិហារ មិនឱ្យរលត់សោះឡើយក្នុងថេរវេលា៣ខែ (រូបលេខ២)។[4] ឯកសារព្រះរាជពិធីទ្វាទសមាសបញ្ជាក់ថា រៀងរាល់ឆ្នាំនៅក្នុងខែអាសាឍ ព្រះមហាក្សត្រទ្រង់តែងយាងបំពេញព្រះរាជពិធីសិតទៀនវស្សាថ្វាយព្រះរតនត្រ័យប្រព្រឹត្តទៅនៅព្រះទីនាំងទេវាវិនិច្ឆ័យ។[5]

ចំពោះក្នុងឱកាសធ្វើកិច្ចចូលព្រះវស្សានៅល្ងាចថ្ងៃ១រោច ខែអាសាឍនោះ ព្រះសង្ឃក្នុងវត្តទាំងអស់ត្រូវជួបជុំគ្នាក្នុងព្រះវិហារ សូត្រប្រារព្ធចូលព្រះវស្សា ដោយមានព្រះចៅអធិការក្នុងវត្តនីមួយៗជាអ្នកដឹកនាំ។ ក្នុងវេលានោះព្រះចៅអធិការវត្តតែងក្រើនរំលឹកដោយធម្មសាសន៍ដូចជា ព្រះសង្ឃគង់ចាំព្រះវស្សាទាំងអស់ត្រូវតាំងចិត្តគង់ស្ថិតនៅក្នុងវត្តដែលបានយកជាទីចាំព្រះវស្សាឱ្យបានគ្រប់ទាំង៣ខែ ឬ៨៨រាត្រី ចៀសវាងកុំឱ្យដាច់

[4] ពេជ្រ សល់ ១៩៦៦: ៤៦ និង ហៀន សុវណ្ណ មរកត "ទៀនវស្សានិងទំនៀមក្នុងសង្គមខ្មែរ" ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/23026 (៥ កក្កដា ២០២២)

[5] ចាប ពិន ១៩៦០: ១-៣៥ និង ធឹង ផុន ផាន់សុផុន ២០០០: ៣១១-៣៤២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

វស្សាដោយមិនចាំបាច់។ ទន្ទឹមនឹងនោះ ព្រះសង្ឃគង់ចាំវស្សាទាំងអស់ត្រូវសិក្សាឱ្យបានច្បាស់និងអនុវត្តតាមធម្មចក្កប្បវត្តនសូត្រ ដោយការវៀរចាកនូវអន្តធម៌ គឺធម៌ជ្រុលទាំងសងខាង ប្រកាន់ខ្ជាប់ក្នុងមជ្ឈិមាបដិបទា ឬផ្លូវកណ្ដាល និងដើរតាមមគ្គទាំង៨។ មិនតែប៉ុណ្ណោះ ត្រូវដាស់តឿនខ្លួនឯងឱ្យបានញឹកញាប់ទៅតាមអភិណ្ហប្បច្ចវេក្ខណធម៌ទាំង ១០ ដែលព្រះបរមគ្រូបានដាស់តឿនឱ្យប្រព្រឹត្តជាប្រចាំ ដើម្បីចម្រើនដល់ខ្លួនជាបព្វជិត។ លើសពីនេះ នៅក្នុងវេលាគង់ចាំព្រះវស្សា ទាំងភិក្ខុសង្ឃនិងសាមណេរទាំងអស់ ត្រូវធ្វើកិច្ចវត្តនមស្សការថ្វាយបង្គំព្រះរតនត្រ័យឱ្យបានទៀងទាត់ទាំងព្រឹក ទាំងល្ងាច និងចម្រើនព្រះបរិត្ត ព្រមទាំងផ្សាយនូវមេត្តធម៌ដល់សព្វសត្វផង (រូបលេខ៣-៤)។

នៅក្នុងវេលាគង់ចាំព្រះវស្សានេះ គេដឹងថាព្រះសង្ឃតែងមានតំណាមយ៉ាងតឹងរ៉ឹងដាច់ខាត គឺមិនអាចនិមន្តចេញក្រៅវត្តឱ្យហួសកន្លងរំលងរាត្រីឡើយ ពោលគឺត្រូវនិមន្តត្រឡប់ចូលវត្តវិញមុនថ្ងៃរះ។ ប៉ុន្តែមានហេតុខ្លះដែលព្រះអង្គទ្រង់ពុទ្ធានុញ្ញាតឱ្យនិមន្តកន្លងរាត្រីបានដូចជា ទៅថែទាំមាតាបិតាឈឺ គ្រូឧបជ្ឈាយ៍អាពាធ ឬពុទ្ធបរិស័ទនៅទីឆ្ងាយនិមន្ត (មិនអាចត្រឡប់មកបាន) ត្រូវសុំសត្តាហៈមុននិមន្តចេញពីវត្ត (បាន៦ យប់ ៦ថ្ងៃ) តែត្រូវត្រឡប់មកវិញមុនថ្ងៃរះនៃថ្ងៃទី៧។ ក្រៅពីការប្រតិបត្តិកិច្ចវត្តតាមគន្លងវិន័យខាងលើ នៅក្នុងសង្គមខ្មែរគេតែងសង្កេតឃើញទម្លាប់តាមស្រុកភូមិខ្លះ ព្រះសង្ឃតែងនិមន្តជ្រើសរើសវត្តដើម្បីគង់ចាំព្រះវស្សា ដែលខ្លួនអាចមានឱកាសសិក្សារៀនសូត្រផង។ បើព្រះសង្ឃក្មេងវស្សាដែលទើបនឹងបួសរៀន ច្រើនតែរៀនធម្មវិន័យ (ថ្នាក់ត្រី ថ្នាក់ទោ ថ្នាក់ឯក) ក្នុងវេលានោះ។ មិនតែប៉ុណ្ណោះ ទម្លាប់ស្រុកខ្លះតែងចាត់វេនគ្នាយកចង្ហាន់មកប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា មិនឱ្យព្រះសង្ឃនិមន្តចេញបិណ្ឌបាត្រឡើយ ពោលគឺគង់នៅក្នុងវត្តសិក្សារៀនសូត្រ ថែទាំវត្តតាមក្រឹត្យវិន័យ (រូបលេខ៥-៦)។ ដោយឡែកក្នុងរយៈពេលចូលព្រះវស្សានេះផងដែរ គេសម្គាល់ឃើញថាបុរាណខ្មែរតែងមានតំណមមិនប្រារព្ធកិច្ចអ្វីឡើយដូចជា រៀមមង្គលការកូនចៅ ឬឡើងផ្ទះថ្មីជាដើម ដ្បិតលោកយល់ថាជាវេលាឥតមានឫក្សល្អ ឥតមានជោគជ័យ និងឥតមានស្រីសួស្តី វៀរលែងតែបុណ្យខ្មោចដែលចៀសខានមិនប្រារព្ធមិនបាន៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# បញ្ជីរូបភាព




រូបលេខ១ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងនូវព្រះធម្មចក្កប្បវត្តនសូត្រប្រោសបញ្ចវគ្គីយភិក្ខុ



រូបលេខ២ ទៀនព្រះវស្សាអុជតម្កល់ក្នុងព្រះវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៣ ព្រះសង្ឃគង់នៅវត្តល្វា (សៀមរាប) កំពុងធ្វើកិច្ចវត្តក្នុងវេលាគង់ចាំព្រះវស្សា



រូបលេខ៤ ព្រះសង្ឃគង់ចាំព្រះវស្សានៅវត្តរាជបូព៌ (សៀមរាប) កំពុងធ្វើកិច្ចវត្តក្នុងព្រះវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៥ ព្រះសង្ឃបោសសម្អាតវត្តក្នុងវេលាគង់ចាំព្រះវស្សា



រូបលេខ៦ ព្រះបន្ទឹជួងជាសញ្ញាត្រូវនិមន្តចូលថ្វាយបង្គំព្រះក្នុងព្រះវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ចាប ពិន

១៩៦០, *ព្រះរាជពិធីទ្វាទសមាស ភាគ៣*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ចាន់ សុជន

២០១៣, *យល់ដឹងពីការចូលវស្សា ដង្ហែទៀនវស្សា និងសាដក*, ការផ្សាយរបស់អ្នកនិពន្ធ, បន្ទាយមានជ័យ

ធឹង ផាន់សុផុន

២០០០, *បុណ្យទំនៀមខ្មែរ៖ ក្រាំងបុណ្យទាំង១២ខែ*, ភាគ២, សាកលវិទ្យាល័យបញ្ញាសាស្ត្រ, ភ្នំពេញ

ពេជ្រ សល់

១៩៦៦, *ពិធីប្រចាំដប់ពីរខែ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ហៀន សុវណ្ណមរកត

២០២២, "ទៀនវស្សានិងទំនៀមក្នុងសង្គមខ្មែរ" ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/23026 (ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត